# ឯកឧត្តម ទេសរដ្ឋមន្ត្រីចមប្រសិទ្ធជួបនាយកចាត់ការទូទៅនៃសាជីវកម្ម Mitusubishi Corporation ប្រចាំកម្ពុជាដែលទើបតែងតាំងថ្មី



នៅរសៀលថ្ងៃទី ១៤ខែកក្កដា ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មបានទទួលជួបលោក **Jun Arii** នាយកចាត់ការទូទៅនៃសាជីវកម្ម Mitusubishi Corporation ប្រចាំកម្ពុជាដែលទើបតែងតាំងថ្មី និងសហការីដើម្បីពិភាកការងារនៅទីស្តីការក្រសួង។

លោក **Jun Arii** បានធ្វើការណែនាំខ្លួននិងបានបញ្ជាក់ថាលោកត្រូវបានតែងតាំងជានាយកចាត់ការទូទៅនៃសាជីវកម្ម Mitusubishi Corporation ដែលមានការិយាល័យនៅទីក្រុងភ្នំពេញកាលពីថ្ងៃ ១ មេសា ឆ្នាំ ២០១៤កន្លងទៅ។លោក **Jun Arii** បានថ្លែងអំណរគុណចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ដែលកន្លងមកក៏ដូចជាបច្ចុប្បន្នបានគាំទ្រចំពោះដំណើការ ក្រុមហ៊ុន Mitusubishi Corporation នៅកម្ពុជា ហើយលោកក៏បានបញ្ជាក់បន្ថែមថាក្រុមហ៊ុនមិនគ្រាន់តែលក់និងចែកចាយផលិតផលម៉ាក Mitusubishi នៅកម្ពុជាប៉ុណ្ណោះទេតែ

ក្រុមហ៊ុនមានគោលដៅផ្ទេរបច្ចេកវិទ្យា និងបទពិសោធន៍ជាមួយនិងការទទួលខុសត្រូវសង្គមផងដែរ។លោកប្រធានចាត់ការទូទៅបានបញ្ជាក់បន្ថែមថាសាជីវកម្ម Mitusubishi Corporation ជាសជីវកម្មដ៏ធំរបស់ជប៉ុនដែលមានអាជីវកម្មច្រើនប្រភេទដូចជា៖ ឧស្សាហកម្មផលិតរថយន្ត ផលិតជណ្តើយន្ត ឧស្សាហកម្មគីមី ផលិតផលអាគ្គីសនី និងឧស្សាហកម្មចំណីអាហារជា ។ល។ នៅតាមបណ្តាប្រទេសជាច្រើននៅលើពិភពលោក។ ក្នុងនោះផ្សាទំនើប អេអន របស់ជប៉ុនដែលទើបសម្ពោធនៅកម្ពុជានាពេលថ្មីៗនេះដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏មានភាគហ៊ុនពីសាជីវកម្ម Mitusubishi ផងដែរ។ ម្យ៉ាងទៀតការកកើតផ្សារនេះមិនអាចកាត់ផ្តាច់ពីការគាំទ្រនិងការជួយទាក់ទាញពី ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងខណៈដែលឯកឧត្តមជាអតីតទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានឡើយ។

ក្នុងជំនួបពិភាក្សាថ្ងៃនេះលោកក៏បានបង្ហាញនូវចំណាប់អារមណ៍លើកម្មវត្ថុអាជីវកម្មមួយចំនួនគឺការបង្កើតវារីអគ្គីសនីខ្នាតតូចសម្រាប់ផ្គត់ផ្គង់ប្រជាពលរដ្ឋរស់តាមដងទន្លេមេគង្គ និងវិស័យទឹកស្អាត។



ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានស្វាគមន៍ និងអបអរសាទរចំពោះលោក**Jun Arii** ដែលត្រូវបានតែងតាំងជានាយកចាត់ការទូទៅនៃសាជីវកម្ម Mitusubishi Corporation។ ឯកឧត្តមបានវាយតំលៃខ្ពស់នៃចំពោះគុណភាពផលិតផល Mitusubishi ហើយដែលប្រជាជនកម្ពុជាបានទទួលស្គាល់រួចមកហើយ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីសក្តានុពលនិងលក្ខណៈអំណោយផលនៃប្រទេសកម្ពុជា ជាពិសេសកម្ពុជាមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច មានសន្តិភាព និងភាពអនុគ្រោះពាណិជ្ជកម្ម ដែលកត្តានេះ ឯកឧត្តមបានអំពាវនាវអោយអ្នកវិនិយោគជប៉ុនមកបណ្តាក់ទុននៅកម្ពុជាអោយបានច្រើនថែមទៀត ដោយឯកឧត្តមបានលើកទឹកចិត្តទៅលើវិស័យមួយចំនួន ដូចជា ឧស្សាហកម្មចំណីអាហារ ឧស្សាហកម្មផលិតបរិក្ខាអេឡិចត្រូនិចនិងអគ្គីសនី ជាពិសេសឧស្សាកម្មគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ។ ដោយឡែកចំពោះចំណាប់ចំពោះការ បង្កើតវារីអគ្គីសនីខ្នាតតូចសម្រាប់ផ្គត់ផ្គង់ប្រជាពលរដ្ឋតាមដងទន្លេមេគង្គ ឯកឧត្តមសូមស្វាគម៍និងក៏បានលើកទឹកចិត្តបន្ថែមចំពោះគំរោងវារីអគ្គីសនីខ្នាតធំដែលអាចផ្គត់ផ្គង់ក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែល

កម្ពុជាបានបង្កើតជាច្រើនកន្លែងនៅតាមតំបន់ជាប់ព្រំដែន។ចំពោះវិស័យទឹកស្អាត ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា ជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ហើយក្រសួងកំពុងយកចិត្តទុកដាក់ ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហសវត្ស ដោយលើកទឹកចិត្តដល់វិស័យឯកជនអាចវិនិយោគលើវិស័យនេះ នៅទីតាំងណាដែលរដ្ឋមិនទាន់មានលទ្ធភាពវិនិយោគ។

